ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

អគ្គនាយកដ្ឋានសុរិយោដី និង ភូមិសាស្ត្រ

លេខ : ១៥៧ អ/សដ-ភ

ភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦

# អគ្គនាយកសុរិយោដី និង ភូមិសាស្ត្រ

## ជំរាបមក

## ប្រធានមន្ទីរ.ដនសស ខេត្ត តាកែវ កំពត កំពង់ធំ និងក្រុងព្រះសីហនុ

**កម្មវត្ថុ** : ស្តីពីការបញ្ជូនសំណុំឯកសារ Pre_LMAP ដែលមានលក្ខណៈមិនគ្រប់គ្រាន់ និងពុំទាន់ចេញប័ណ្ណ ទៅមន្ទីរ ដនសស ដើម្បីបំពេញសំណុំបែបបទ និងធ្វើការចេញប័ណ្ណជូនម្ចាស់កម្មសិទ្ធិករ ។

**យោង** :
- ចំណារឯកភាពឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការចាត់បញ្ជូនសុំណុំឯកសារគំរោងសាកល្បងដែលពុំត្រឹមត្រូវ និងពុំទាន់ចេញប័ណ្ណ ដល់ខេត្ត-ក្រុងទាំង ៤ ដើម្បីធ្វើការចេញប័ណ្ណជូន ។
- លិខិតលេខ ១៧ ន/អភិ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីអំពីរបាយការណ៍បាត់ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

តបតាមកម្មវត្ថុ និង យោងខាងលើ អគ្គនាយកដ្ឋានសូមជំរាបមកលោកប្រធានមន្ទីរ ដនសស អនុវត្តគំរោង Pre_LMAP ជ្រាបថា : នាយកដ្ឋានអភិរក្សសុរិយោដី បានបញ្ចប់ដំណើរការរៀបចំទុកដាក់ឯកសារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធរបស់ខេត្ត-ក្រុង អនុវត្តគំរោង Pre_ LMAP ចំនួន ៤ មាន : ខេត្តតាកែវ, ខេត្តកំពត, កំពង់ធំ និង ក្រុងព្រះសីហនុ ដែលមាន ១៣ ឃុំ ស្មើនឹង ៦២ ភូមិ ដែលមានក្បាលដីសរុបចំនួន ៤៩១៤៥ ក្បាលដី ក្នុងនោះមានក្បាលដីនៅសល់ និងពុំទាន់ចេញប័ណ្ណសរុបចំនួន ៣៤០៨ ក្បាលដី ដែលត្រូវចាត់បញ្ជូនទៅខេត្ត-ក្រុងសាម៉ីទាំង ៤ ដើម្បីបំពេញសំណុំបែបបទបន្ថែម និង ធ្វើការចេញប័ណ្ណ ក្នុងនោះមាន ខេត្ត តាកែវ ១២៦៨ ក្បាលដី, ក្រុងព្រះសីហនុ ១០៣២ ក្បាលដី, ខេត្តកំពត ៦០០ ក្បាលដី និង ខេត្តកំពង់ធំ ចំនួន ៥០៨ ក្បាលដី ។

(សូមជូនភ្ជាប់ តារាងសរុប និងតារាងលំអិត នៃចំនួនក្បាលដី និង ក្បាលដីដែលបាត់ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីរបស់ខេត្ត-ក្រុងទាំង៤ )

សំណុំឯកសារដែលនៅសល់ទាំងនេះ អគ្គនាយកដ្ឋានពិនិត្យឃើញថា មានឯកសារដែលត្រូវបោះបង់ចោល ចំនួន ២៤៧៦ សំណុំឯកសារ ដោយខ្វះឯកសាររលុប និងមិនមានលក្ខណៈគ្រប់គ្រាន់, ក្បាលដីមានប័ណ្ណ

សំគាល់សិទ្ធិ ធ្វើការលក់-ទិញ មិនទាន់ផ្ទេរកាត់ឈ្មោះ ១៦៧ សំណុំឯកសារ, ក្បាលដីទំនាស់ ៣៤ សំណុំឯកសារ ក្បាលដីគ្មានទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ៦៩ សំណុំឯកសារ, ក្បាលដីពុំទាន់បោះពុម្ពប័ណ្ណ ៥៦ សំណុំឯកសារ, និងក្បាលដីគ្មានទិន្នន័យ ៦០៦ សំណុំឯកសារ ដោយមន្ត្រីជំនាញបានបំពេញលេខក្បាលដី លើទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងគូរប្លង់ក្បាលដី តែម្ចាស់ដីមិនបានមកផ្តល់ពត៌មាន ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ អគ្គនាយកដ្ឋាន សូមធ្វើការណែនាំករណីទាំងនេះ ដូចមានចំណុចខាងក្រោម :

១- ចំពោះការចេញប័ណ្ណនេះអាចចេញប័ណ្ណជូនម្ចាស់ដីបាន ទោះក្នុងករណីប្រមូលលិខិតរលាបបានបន្ថែមក្តី មិនបានក្តី ព្រោះបានធ្វើការបិទផ្សាយជាសាធារណៈ និងបានចុះហត្ថលេខាសំរេចលើឯកសារវិនិច្ឆ័យរួចហើយ ។

២- ទាក់ទងនឹងក្បាលដី លក់-ទិញ មានប័ណ្ណសំគាល់សិទ្ធិ ផ្ទេរមិនកាត់ឈ្មោះ តម្រូវអោយបំពេញកាតព្វកិច្ចបង់ពន្ធប្រថាប់ត្រាជាមុនសិនទើបធ្វើការចេញប័ណ្ណជូនបាន ។ ការបង់ពន្ធប្រថាប់ត្រាអាចធ្វើនៅលើទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

៣- ចំពោះក្បាលដីទំនាស់មានករណីដូចខាងក្រោម :

ក- ប្រសិនបើវិវាទត្រូវបានបញ្ចប់ ហើយមានខ្លឹមសារដូចគ្នាជាមួយនឹងទិន្នន័យដែលបានបិទប្រកាសនោះ យើងអាចធ្វើការចេញប័ណ្ណជូនបាន ។

ខ- ប្រសិនបើមានការសំរេចជាស្ថាពរ ខុសគ្នាជាមួយទិន្នន័យដែលបានបិទផ្សាយជាសាធារណៈ ឬក៏មានការកែប្រែលក្ខណៈរូបនៃក្បាលដី នោះអ្នកទទួលសិទ្ធិក្រោយបញ្ចប់វិវាទត្រូវដាក់ពាក្យសុំមករដ្ឋបាលសុរិយោដី ស្រុក-ខណ្ឌ តាមរយៈមេឃុំ-ចៅសង្កាត់ ។ ចំពោះនីតិវិធី ដូចមានណែនាំក្នុងសារាចរស្តីពីការចុះបញ្ជីដីបំពេញបន្ថែម ។

គ- ប្រសិនបើបញ្ចប់វិវាទ ហើយមានការពុះបំបែកបន្ថែមក្បាលដី ។ លក្ខណៈបែបនេះទាក់ទងនឹងការចុះបញ្ជីដីបំពេញបន្ថែមលើតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចហើយ ។

៤- ក្បាលដីគ្មាន form ជាក្បាលដី ដែលត្រូវចុះបញ្ជីនៅក្នុងទិន្នន័យគោល និងប្លង់សុរិយោដីរួចហើយ តែបាត់ទំរង់បែបបទនៃការប្រមូលទិន្នន័យ ។ ចំណុចនេះអាចមានករណីដូចខាងក្រោម :

ក- អាចបោះពុម្ពប័ណ្ណចែកជូនដល់ម្ចាស់រួចហើយ ករណីនេះត្រូវកសាងទំរង់បែបបទថ្មី ដោយយោងទំរង់បែបបទដែលបានចុះបញ្ជីរួចហើយ ។

ខ- ពុំទាន់បោះពុម្ពប័ណ្ណ ករណីនេះត្រូវកសាងទំរង់បែបបទថ្មី ដោយយោងទំរង់បែបបទដែលបានចុះបញ្ជីរួច ហើយធ្វើការចេញប័ណ្ណជូនម្ចាស់កម្មសិទ្ធិករ ។

៥- ក្បាលដីដែលពុំទាន់បោះពុម្ពប័ណ្ណ ជាក្បាលដីទាក់ទងនឹងការ លក់-ទិញ មានប័ណ្ណសំគាល់សិទ្ធិ ហើយផ្ទេរមិនកាត់ឈ្មោះ ប៉ុន្តែពុំទាន់ធ្វើការបោះពុម្ពប័ណ្ណ ។ ករណីនេះដូចគ្នានឹងចំណុចលេខ ២ ខាងលើ តម្រូវអោយបំពេញកាតព្វកិច្ចបង់ពន្ធប្រថាប់ត្រា ទើបធ្វើប្រគល់វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុជូនបាន ។ ចំពោះប័ណ្ណសំគាល់សិទ្ធិត្រូវប្រមូលនិងធ្វើមោឃភាព ។

៦- ក្បាលដីគ្មានទិន្នន័យ ជាក្បាលដីដែលមន្ត្រីជំនាញបំពេញលេខក្បាលដីលើទំរង់បែបបទនៃការប្រមូលទិន្នន័យ និងប្លង់ក្បាលដី តែម្ចាស់ដីមិនចូលរួមផ្តល់ពត៌មានក្នុងការចុះបញ្ជី ។ ករណីនេះ ប្រសិនបើមានការស្នើសុំចុះបញ្ជី ត្រូវអនុវត្តការចុះបញ្ជីបំពេញបន្ថែមលើតំបន់ដែលបានធ្វើការវិនិច្ឆ័យរួចហើយ ។

ចំពោះក្បាលដីដែលនៅសល់ហើយពុំមានការស្នើសុំចុះបញ្ជីមានជំរើស ២ យ៉ាងក្នុងការចុះបញ្ជីបំពេញបន្ថែម :

ក- ប្រកាសចុះបញ្ជីបំពេញបន្ថែមលើក្បាលដីដែលនៅសេសសល់ទាំងភូមិតែម្តង

ត្រូវជូនដំណឹងដល់អ្នកដែលពុំបានចុះបញ្ជីលើកដំបូងមកចូលរួមចុះបញ្ជី ដោយត្រូវអោយអ្នកស្នើសុំដាក់ពាក្យសុំចុះបញ្ជីដីមករដ្ឋបាលសុរិយោដីស្រុក-ខណ្ឌតាមរយៈមេឃុំ-ចៅសង្កាត់ ។ ក្នុងសេចក្តីជូនដំណឹងនេះត្រូវកំណត់ថ្ងៃខែនៃការចុះបញ្ជីបំពេញបន្ថែម និងត្រូវមានឃ្លាមួយដែលបញ្ជាក់យ៉ាងច្បាស់ថា នេះជាឱកាសចុងក្រោយសំរាប់អ្នកកាន់កាប់ដីដែលត្រូវមកចុះបញ្ជីបំពេញបន្ថែមសំរាប់ការចុះបញ្ជីលើកដំបូង ។

ខ- ប្រកាសចុះបញ្ជីក្បាលដីទាំងអស់ដែលនៅសល់ក្នុងឃុំទាំងមូល

ប្រសិនបើការចុះបញ្ជីលើកដំបូងបានបញ្ចប់ទូទាំងឃុំនោះ ត្រូវជូនដំណឹងដល់អ្នកដែលពុំបានចូលរួមចុះបញ្ជីលើកដំបូងទៅតាមភូមិនីមួយៗក្នុងឃុំទាំងមូល មកដាក់ពាក្យសុំចុះបញ្ជីបំពេញបន្ថែម ដូចបានរៀបរាប់ខាងលើ និងធ្វើការចេញប័ណ្ណដែលនៅសេសសល់ទូទាំងឃុំតែម្តង ។

ចំពោះពត៌មានដែលទទួលបានក្នុងការចុះបញ្ជីបន្ថែមត្រូវ :

- បញ្ជីឈ្មោះម្ចាស់ដី ឬ សៀវភៅគោលបញ្ជីដីធ្លី ដែលបានកត់ត្រាក្បាលដីចុះបញ្ជីរួចហើយ ប៉ុន្តែពុំមានពត៌មានដោយម្ចាស់ដីពុំបានចូលរួម អាចសរសេរពត៌មានបន្ថែមលើក្បាលដីនោះបាន ។

- ប៉ុន្តែប្រសិនបើមានបន្ថែមលេខក្បាលដីថ្មី អាចសរសេរពត៌មានបន្ថែមបាននៅសន្លឹកចុងក្រោយនៃសន្លឹកសៀវភៅគោលបញ្ជីដីធ្លី ។

- ចំពោះប្លង់សុរិយោដីអាច Update បន្ថែមបានដោយធ្វើការ Update លើប្លង់សុរិយោដីដែលបានសំរេចហើយ ឬក៏អាចបោះពុម្ពប្លង់សុរិយោដីថ្មីបាន ហើយដាក់ជូនសមត្ថកិច្ចដែលមានសិទ្ធិសំរេចលើកមុន ។

៧- ក្នុងករណីក្បាលដីដែលសេសសល់ពុំត្រឹមត្រូវ និងពុំទាន់ចេញប័ណ្ណទាំងនេះបានផ្ទេរទៅម្ចាស់ថ្មី ត្រូវបំពេញទំរង់បែបបទជូនទៅម្ចាស់ថ្មី ដោយយោងតាមទំរង់បែបបទដែលមាន ហើយអនុវត្តនីតិវិធីខាងលើ ដើម្បីធ្វើការចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុជូនម្ចាស់ថ្មី ។

៨- សន្លឹកប័ណ្ណដែលត្រូវចេញជូន ត្រូវយកគំរូប័ណ្ណថ្មីដែលកំពុងប្រើប្រាស់ដោយគំរោង LMAP ។

៩- ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងឯកសាររណបដែលពាក់ព័ន្ធ ដែលបានចាត់បញ្ជូនទៅខេត្ត-ក្រុងសាម៉ីទាំង ៤ ដើម្បីបំពេញ និងធ្វើការចេញប័ណ្ណ ត្រូវបញ្ជូនត្រឡប់មកនាយកដ្ឋានអភិរក្សសុរិ-យោដីវិញនៅពេលចេញប័ណ្ណជូនម្ចាស់កម្មសិទ្ធិកររួចហើយ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកប្រធានមន្ទីរ ដនសស អនុវត្តគំរោង Pre_LMAP ខេត្ត តាកែវ. កំពត. កំពង់ធំ. និងក្រុងព្រះសីហនុ ចាត់បញ្ជូនមន្ត្រីមកទទួលយកសំណុំឯកសារដែលពុំត្រឹមត្រូវពី នាយកដ្ឋានអភិរក្សសុរិយោដី ដើម្បីធ្វើការចេញប័ណ្ណជូនម្ចាស់កម្មសិទ្ធិករទាំងនោះ ។

អគ្គនាយក

លឹម វ៉ាន់

<u>ចម្លងជូន</u>

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- នាយកចាត់ការគំរោង LMAP
- នាយកដ្ឋាន អភិរក្សសុរិយោដី
- ឯកសារ-កាលប្បវត្តិ